**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៣១៦.សរណ

ថ្ងៃ ចន្ទ ៦កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២២

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ ស្តីពីការបង្កលក្ខណៈងាយស្រួលដល់គ្រប់គណបក្សនយោបាយ ដែលបានចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃ ធ្វើសកម្មភាពដើម្បីចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣។

**យោង** ៖- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីគណបក្សនយោបាយ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** ជ្រាបថា ដើម្បីបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ បានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ ខាងមុខ ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងដើម្បីធានាការអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រសួងមហាផ្ទៃសូមស្នើឱ្យរដ្ឋបាលរាជធានី ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ត្រូវបង្កលក្ខណៈងាយស្រួលដល់គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយនៅក្រសួងមហាផ្ទៃ ក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ ដូចខាងក្រោម៖

**១.អំពីការបើកទីស្នាក់ការគណបក្សនយោបាយ៖**

ចំពោះការបើកទីស្នាក់ការគណបក្សនយោបាយ នៅតាមលំនៅដ្ឋានឯកជន ឬទីតាំងឯកជននានា ត្រូវមានការយល់ព្រមជាមុនពីម្ចាស់កម្មសិទ្ធិទាំងនោះ ដោយមានកិច្ចសន្យាជួល ឬកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ។ ទន្ទឹមនេះ សាមីគណបក្សនយោបាយនីមួយៗគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់ អំពីការបើកទីស្នាក់ការគណបក្សនយោបាយតែប៉ុណ្ណោះ ដោយមិនតម្រូវឱ្យសុំការអនុញ្ញាតជាមុនពីអាជ្ញាធរឡើយ។ បន្ទាប់ពីទទួលបានលិខិតជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយរួចហើយ អាជ្ញាធរឃុំ សង្កាត់ ត្រូវរាយការណ៍ជូនអាជ្ញាធរក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយសមត្ថកិច្ច



ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

ពាក់ព័ន្ធ ក្នុងការគាំទ្រ និងសហការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន។ គណបក្សនយោបាយសាមី ឬម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងឯកជន ត្រូវផ្តល់នូវកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រកបដោយការយោគយល់អំពីវិធានការសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ។

## ២.អំពីការលើកផ្លាកសញ្ញាគណបក្ស៖

ការលើកផ្លាកសញ្ញាគណបក្សនៅទីស្នាក់ការរបស់ខ្លួន ឬលំនៅដ្ឋានឯកជន ឬទីតាំងឯកជន ត្រូវមានការយល់ព្រមជាមុនពីម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងទាំងនោះ។ ទន្ទឹមនេះ សាមីគណបក្សនយោបាយនីមួយៗគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់ អំពីការលើកផ្លាកសញ្ញាគណបក្សតែប៉ុណ្ណោះ ដោយមិនតម្រូវឱ្យសុំការអនុញ្ញាតជាមុនពីអាជ្ញាធរឡើយ លើកលែងតែការលើកផ្លាកសញ្ញាគណបក្សនៅតាមទីសាធារណៈ ទីប្រជុំជន ឬតាមដងផ្លូវនានា។ បន្ទាប់ពីទទួលបានលិខិតជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយរួចហើយ អាជ្ញាធរឃុំ សង្កាត់ ត្រូវរាយការណ៍ជូនអាជ្ញាធរក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការគាំទ្រ និងសហការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន។ គណបក្សនយោបាយសាមី ឬម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងឯកជន ត្រូវផ្តល់នូវកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រកបដោយការយោគយល់អំពីវិធានការសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ។

ចំពោះការលើកផ្លាកសញ្ញាគណបក្សនយោបាយនៅតាមទីសាធារណៈ ទីប្រជុំជន ឬតាមដងផ្លូវនានា សាមីគណបក្សនយោបាយត្រូវសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។ ពាក្យសុំលើកផ្លាកសញ្ញាគណបក្សនយោបាយដូចករណីខាងលើនេះ ត្រូវដាក់ជូនទៅអាជ្ញាធរឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងតិច ៣(បី)ថ្ងៃ មុនការលើកផ្លាកសញ្ញា។ អាជ្ញាធរឃុំ សង្កាត់ ត្រូវពិនិត្យពិចារណាលើសំណើនេះក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន អំពីបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ពិសេសសុវត្ថិភាពចរាចរណ៍ និងសោភ័ណភាពសាធារណៈ ហើយត្រូវឆ្លើយតបចំពោះសំណើសុំក្នុងរយៈពេល ១(មួយ)ថ្ងៃ បន្ទាប់ពីទទួលសំណើ។ ក្នុងករណីអាជ្ញាធរឃុំ សង្កាត់ មិនអាចសម្រេចបាន អាជ្ញាធរឃុំ សង្កាត់ ត្រូវធ្វើការស្នើសុំយោបល់ពីអាជ្ញាធរក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត រួចហើយអាជ្ញាធរឃុំ សង្កាត់ ត្រូវឆ្លើយតបទៅសាមីគណបក្សនយោបាយវិញយ៉ាងតិច ១(មួយ)ថ្ងៃ មុនថ្ងៃលើកផ្លាកសញ្ញា។

## ៣.អំពីការជួបប្រជុំនយោបាយ ឬការជួបប្រជុំមន្ត្រីគណបក្ស៖

ការជួបប្រជុំនយោបាយ ឬការជួបប្រជុំមន្ត្រីគណបក្ស អាចរៀបចំធ្វើឡើងនៅទីស្នាក់ការកណ្តាល ឬទីស្នាក់ការសាខាគណបក្សនីមួយៗ ឬលំនៅដ្ឋានឯកជន ឬទីតាំងឯកជន។ ចំពោះការជួបជុំនៅតាមលំនៅដ្ឋានឯកជន ឬទីតាំងឯកជន ត្រូវមានការយល់ព្រមពីម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងទាំងនោះ។ ទន្ទឹមនេះ សាមីគណបក្សនយោបាយនីមួយៗគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់អំពីការជួបប្រជុំនយោបាយ ឬការជួបប្រជុំមន្ត្រីគណបក្សតែប៉ុណ្ណោះ ដោយមិនតម្រូវឱ្យសុំការអនុញ្ញាតជាមុនពីអាជ្ញាធរឡើយ លើកលែងតែការជួបប្រជុំនយោបាយនៅតាមទីសាធារណៈ។ បន្ទាប់ពីទទួលបានលិខិតជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយរួចហើយ អាជ្ញាធរឃុំ សង្កាត់ ត្រូវរាយការណ៍ជូនអាជ្ញាធរក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការគាំទ្រ និងសហការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន។ គណបក្សនយោបាយសាមី ឬម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងឯកជន ត្រូវផ្តល់នូវកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រកបដោយការយោគយល់អំពីវិធានការសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ។

ចំពោះការជួបប្រជុំនយោបាយនៅតាមទីសាធារណៈ ដែលរៀបចំដោយគណបក្សនយោបាយ ហើយដែលមិនមែនជាសកម្មភាពបាតុកម្ម កូដកម្មដែលស្ថិតក្នុងក្របខណ្ឌច្បាប់ដោយឡែក សាមីគណបក្សនយោបាយត្រូវសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។ ពាក្យសុំជួបប្រជុំនយោបាយដូចករណីខាងលើនេះ ត្រូវដាក់ជូនទៅអាជ្ញាធរឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងតិច ៣(បី)ថ្ងៃ មុនការជួបប្រជុំ។ អាជ្ញាធរឃុំ សង្កាត់ ត្រូវពិនិត្យពិចារណាលើសំណើនេះក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន អំពីបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ពិសេសសុវត្ថិភាពចរាចរណ៍ និងអនាម័យសាធារណៈ ហើយត្រូវឆ្លើយតបចំពោះសំណើសុំក្នុងរយៈពេល ១(មួយ)ថ្ងៃ បន្ទាប់ពីទទួលសំណើ។ ក្នុងករណីអាជ្ញាធរឃុំ សង្កាត់ មិនអាចសម្រេចបាន អាជ្ញាធរឃុំ សង្កាត់ ត្រូវធ្វើការស្នើសុំយោបល់ពីអាជ្ញាធរក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត រួចហើយអាជ្ញាធរឃុំ សង្កាត់ ត្រូវឆ្លើយតបទៅសាមីគណបក្សនយោបាយវិញយ៉ាងតិច ១(មួយ)ថ្ងៃ មុនថ្ងៃជួបប្រជុំ។

ការជួបប្រជុំនយោបាយនៅតាមទីសាធារណៈដូចករណីខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវពិគ្រោះពិភាក្សាជាមួយគណបក្សនយោបាយសាមី អំពីវិធានការចាំបាច់ដែលគណបក្សនយោបាយត្រូវផ្តល់កិច្ចសហការ និងការយោគយល់គ្នាទៅវិញទៅមក អំពីបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ និងអនាម័យសាធារណៈ រួមទាំងវិធានការសុខាភិបាល។

សូមជូនភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្រសួងមហាផ្ទៃ ចំនួន០១ច្បាប់។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត** ជ្រាប និងត្រូវចាត់ចែងផ្សព្វផ្សាយដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីផ្តល់កិច្ចសហការគាំទ្រ និងសម្របសម្រួលក្នុងការអនុវត្តកិច្ចការខាងលើឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ក្រសួងយុត្តិធម៌

  (ដើម្បីជូនជ្រាប)
- គ្រប់គណបក្សនយោបាយ

  (ដើម្បីសហការអនុវត្ត)
- ឯកសារ - កាលប្បវត្តិ